# របាយការណ៍ប្រចាំត្រីមាសទីបួន

## ៣១ ធ្នូ ២០២០

# អ រិម អេ ( ខេមបូឌា ) ម.ក

# RMA ( CAMBODIA ) PLC.

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ២០២០ | ២០១៩ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤១៨.៩២៩.៥៧៧ | ៤៩៥.៦២៣.៥៣៧ |
| បំណុលសរុប | ២៣៧.២២១.៥១៩ | ៣៧៥.៤២០.០៧៦ |
| មូលធនក្រុមហ៊ុនសរុប | ១៨១.៧០៨.០៥៨ | ១២០.២០៣.៤៦១ |
| **ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល)** | **ត្រីមាសទី៤ ២០២០** | **ត្រីមាសទី៤ ២០១៩** |
| ចំណូលសរុប | ២៦៥.២៩៤.៩៣៤ | ២១៩.៨០១.៨០១ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ១៦.៥៥១.០១៧ | ៣.៧១០.៨៩២ |
| ប្រាក់ចំណេញ/(ខាត)ក្រោយបង់ពន្ធ | ១៤.៤១៨.២៤២ | ៥.៦៧៥.៩២៣ |
| ចំណូលផ្សេងៗសង្ខេបសរុប (Total Comprehensive Income) | ១២.១០៥.៣៨៤ | ៤.៩០២.៨៩៣ |
| **អនុបាតហិរញ្ញវត្ថុ** | **២០២០** | **២០១៩** |
| អនុបាតសាធនភាព | -១,៣១ | ៣,១២ |
| អនុបាតចរន្ត (Current Ratio) | -២,៣៨ | ១,២២ |
| អនុបាតចរន្តលឿន (Quick Ratio) | -១,៣៥ | មិនមាន |

| អនុបាតចំណេញភាព | ត្រីមាសទី ៤<br>២០២០ | ត្រីមាសទី ៤<br>២០១៩ |
|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ២,៦% | ១,៣% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ៨,0% | ៥,៥% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៥,៣% | ១៤,៩% |
| គម្លាតចំណេញ (Profit Margin) | ៥,៤% | ២,៦% |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ<br>(EPS) (គិតជាពាន់រៀល) | ១២,១០៥ | ៤,៩០៣ |
| អនុបាតលទ្ធភាពសងការប្រាក់<br>(Interest Coverage Ratio) | ៨,៥០ | ២,៣៤ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ឆ្នាំ ២០២០ | ឆ្នាំ ២០១៩ |
|---|---|---|
| ចំណូលសរុប | ១.១៩៦.០៥០.១៧៧ | ១.១៤៨.៥៨៥.៣៥៤ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ១១០.៦៧១.៨១៧ | ១១៣.៣៩៧.៦១៨ |
| ប្រាក់ចំណេញ/(ខាត)ក្រោយបង់ពន្ធ | ៨៩.០៥១.២៦៦ | ៩០.៦២៨.៨៨៣ |
| ចំណូលផ្សេងៗសង្ខេបសរុប<br>(Total Comprehensive Income) | ៨៧.៦១៣.៩៣០ | ៩១.៧០៥.៥០៤ |

| អនុបាតចំណេញភាព | ឆ្នាំ ២០២០ | ឆ្នាំ ២០១៩ |
|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ១៩,២% | ២៤,៥% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ៥៨,0% | ១0២,៥% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៥,៨% | ១៦,៤% |
| គម្លាតចំណេញ (Profit Margin) | ៧% | ៧,៩% |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ<br>(EPS) (គិតជាពាន់រៀល) | ៨៧.៦១៤ | ៩១.៧០៦ |
| អនុបាតលទ្ធភាពសងការប្រាក់<br>(Interest Coverage Ratio) | ៨,៤៨ | ១២,៨២ |
| ភាគលាភក្នុងមួយភាគហ៊ុន<br>(គិតជាពាន់រៀល) | ២៦.១០៩ | ៣០.៣៩០ |
| អនុបាតសំខាន់ផ្សេងៗ | មិនមាន | មិនមាន |

# ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប




## មូលធនសរុប (គិតជាពាន់រៀល)

ឆ្នាំ២០២០
១៨៤.៩៤៩.៤៨៦

ឆ្នាំ២០១៩
១២០.២០៣.៤៦១

### RETURN ON AVERAGE EQUITY
ផលលើមូលធនជាមធ្យម

ត្រីមាសទី៤ ឆ្នាំ២០២០
១០,០%

ត្រីមាសទី៤ ឆ្នាំ២០១៩
៥,៥%

### RETURN ON AVERAGE EQUITY
ផលលើមូលធនជាមធ្យម

ឆ្នាំ២០២០
៥៩,៥%

២០១៩
១០២,៥%

# ប្រាក់ចំណូល និងចំណូលសុទ្ធ (គិតជាពាន់រៀល)



## សមាជិកក្រុមប្រឹក្សាភិបាល



លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល



លោក ងន សាំង
អភិបាលប្រតិបត្តិ



លោក Tom Whitcraft
អភិបាលមិនប្រតិបត្តិ



លោក Chris Manley
អភិបាលមិនប្រតិបត្តិ



លោក Ith Vichit
អភិបាលឯករាជ្យ

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ **ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក** (តទៅនេះហៅកាត់ថា "**ក្រុមហ៊ុន RMAC**") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)។

នៅក្នុងឆ្នាំ២០២០ ក្រុមហ៊ុន RMAC បានឃើញការលក់ និងប្រាក់ចំណេញសម្រាប់ដំណាច់ត្រីមាសទី៤ កើនឡើងរៀងគ្នាចំនួន +២០,៧ភាគរយ និង+១៥៤,០ភាគរយខ្ពស់ជាងលទ្ធផលដំណាច់ត្រីមាសទី៤នៃឆ្នាំ២០១៩។ ជាក់ស្តែង ភាពរឹងមាំនៃប្រតិបត្តិការរបស់ក្រុមហ៊ុនបានបង្ហាញឲ្យឃើញពីសក្តានុពលរបស់ពាណិជ្ជនាមក្រុមហ៊ុនយើង និងភាពជោគជ័យរបស់ក្រុមកាងាររបស់ក្រុមហ៊ុនទៅលើផ្នែករថយន្ត គ្រឿងចក្រផ្នែកកសិកម្ម និងឧស្សាហកម្មធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជាផងដែរ។

នៅអំឡុងឆ្នាំ២០២០ ការលក់ចាប់ផ្តើមពីភាពជោគជ័យបំផុតនៅក្នុងដំណាច់ត្រីមាសទី១ ដែលមានការកើនឡើងពីលើតួលេខនៃការលក់ក្នុងដំណាច់ត្រីមាសទី១ ឆ្នាំ២០១៩ ចំនួន +៥៥,២ភាគរយ ប៉ុន្តែកំណើននេះបានធ្លាក់ចុះវិញនៅក្នុងដំណាច់ត្រីមាសទី២ឆ្នាំ២០២០ រហូតដល់ចំនួន -៤០,៩ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ ដោយសារជម្ងឺរាតត្បាតនៃកូវីដ-១៩។ យ៉ាងណាមិញក្នុងដំណាច់ត្រីមាសទី៣ឆ្នាំ២០២០ កំណើននៃការលក់មានការកើនឡើងវិញ បើទោះបីជាទាបជាងឆ្នាំ២០១៩ ចំនួន -០,៩ភាគរយក៏ដោយ។

ទោះបីជាស្ថានភាពនៃការរាតត្បាតវីរុសកូវីដ-១៩ ត្រូវបានគ្រប់គ្រងបានយ៉ាងល្អនៅក្នុងប្រទេសកម្ពុជាខណៈពេលដែលមានការឆ្លងរហូតទៅដល់ ៤៧៩ករណី និងបានជាសះស្បើយចំនួន ៤៦៣ករណីហើយយ៉ាងណាក៏ដោយផលប៉ះពាល់ចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជានៅតែមានភាពខ្លាំងក្លាលើវិស័យចំបងៗមួយចំនួន ដូចជាវិស័យទេសចរណ៍ វិស័យសំណង់ វិស័យកាត់ដេរ និងវិស័យបដិសណ្ឋារកិច្ច។ ការចំណាយរបស់រាជរដ្ឋាភិបាលនៅក្រសួងមួយចំនួនមានការកាត់បន្ថយចំនួន ៥០ ភាគរយបើធៀបទៅនឹងឆ្នាំមុន។

ក្រុមហ៊ុន RMAC បានចាត់វិធានការណ៍មួយចំនួនដើម្បីទប់ទល់ជាមួយនឹងបញ្ហាប្រឈមនានាក្នុងឆ្នាំ២០២០ តាមរយៈការកាត់បន្ថយសារពើភណ្ឌ និងការបម្រុងទុកនូវសាច់ប្រាក់ រួមទាំងការសន្សំសំចៃចំណាយផ្សេងៗផងដែរ។ ជាមួយគ្នានេះផងដែរ ក្រុមហ៊ុននៅតែបន្តធ្វើការសម្ពោធផលិតផលពីក្រុមហ៊ុនរបស់យើងដោយផ្តោតលើតម្រូវការរបស់អតិថិជនក្នុងប្រទេសកម្ពុជា និងដើម្បីឲ្យប្រាកដថាក្រុមហ៊ុនបានផ្តល់ដល់អតិថិជននូវបច្ចេកវិទ្យាចុងក្រោយបំផុតដែលផ្តោតសំខាន់ទៅលើការកាត់បន្ថយប្រើប្រេងឥន្ធៈ និងសុវត្ថិភាពរបស់អតិថិជនទៅលើផលិតផលដែលបានលក់របស់ក្រុមហ៊ុនយើង។

ក្នុងឆ្នាំ២០២០ បានបើកបង្ហាញឲ្យឃើញពីផលិតផលដូចជាៈ

- The All-New Land Rover Defender
- The All-Fully Electric Jaguar iPace
- The Ford Everest 2.0L Bi-Turbo
- The John Deere 6095 (95 HoursePower)

ក្រុមហ៊ុន RMAC នឹងបន្តអនុវត្តយុទ្ធសាស្ត្រអាជីវកម្មជាក្រុមហ៊ុនផ្គត់ផ្គង់ឈានមុខគេផ្នែកយានយន្ត សំណង់ គ្រឿងបរិក្ខារកសិកម្ម និងគ្រឿងបរិក្ខារជំនួយ (materials handling equipment) ដែលមានស្តង់ដារលំដាប់ពិភពលោកនៅប្រទេសកម្ពុជា។ ក្រុមហ៊ុន RMAC បានផ្តោតសំខាន់និងយកចិត្តទុកដាក់ជាបន្តបន្ទាប់ក្នុងនាមជាក្រុមហ៊ុនមួយដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជាលើការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពគ្រប់គ្រង និងការឆ្ពោះទៅមុខក្នុងរយៈពេលវែងរបស់ក្រុមហ៊ុនក្នុងការស្វែងយល់ពីទំនួលខុសត្រូវលើតួនាទី សង្គម និងបរិស្ថានផងដែរ។

ខ្ញុំបាទតំណាងឲ្យក្រុមប្រឹក្សាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈគ្រប់គ្រងចំពោះការដឹកនាំ ការព្យាយាម និងការប្តេជ្ញាចិត្ត ជាពិសេសភាពឈ្លាសវៃក្នុងការឆ្លើយតបទៅនឹងបម្រែបម្រួលស្ថានការណ៍ដ៏លំបាកមួយរយៈកន្លងមកនេះ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណដល់អតិថិជនដ៏មានភក្តីភាព និងបុគ្គលិកទាំងអស់ចំពោះការលះបង់ដ៏មិនរុញរា និងរាល់កម្លាំងកាយចិត្តដែលបានផ្តល់ជូនដល់ក្រុមហ៊ុនយើងខ្ញុំ។

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ អិម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA)
PLC
KINGDOM OF CAMBODIA

លោក Kevin Whitcraft

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០២១

## មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ...... II
សមាជិកក្រុមប្រឹក្សាភិបាល ...... VII
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ...... VIII
ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ...... 2
ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ...... 2
ខ. សកម្មភាពអាជីវកម្ម ...... 2
គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស ...... 3
ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ...... 5
ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ...... 5
ខ. រចនាសម្ព័ន្ធប្រាក់ចំណូល ...... 6
ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ...... 7
ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង ...... 8
ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ...... 8
ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ ...... 12
គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល ...... 13
ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ ...... 13
ង. ផលប៉ះពាល់នៃអតិផរណា ...... 13
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ...... 13
ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ...... 14

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| | |
|---|---|
| **ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ** | អ អិម អេ (ខេមបូឌា) ម.ក |
| **ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង** | RMA (CAMBODIA) PLC |
| **លេខកូដស្តង់ដារ** | KH2000121A44 |
| **អាសយដ្ឋាន** | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| **លេខទូរស័ព្ទ** | +៨៥៥ (០) ២៣ ៨៨៣ ៨៨៨ / ១២ ៨៦៧ ៦៩៧ |
| **លេខទូរសារ** | +៨៥៥ (០) ២៣ ៨២៦ ៧៥២ |
| **គេហទំព័រ** | www.cambodia.rmagroup.net |
| **អ៊ីម៉ែល** | saing.ngorn@rmagroup.net |
| **លេខចុះបញ្ជីក្រុមហ៊ុន** | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| **លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន** | ០០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| **ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ** | លោក ងន សាំង |
| **លេខាធិការក្រុមហ៊ុន** | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Jaguar Land Rover, John Deere, TCM, JCB, FUSO, និង Piaggio។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងការតម្លើងជំបូងគេបង្អស់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាសនេះ រួមមានដូចខាងក្រោម៖

**ការដាក់សម្ពោធជាផ្លូវការរបស់ The All-New Land Rover Defender**

នាថ្ងៃទី៣១ ខែកក្កដា ២០២០ ក្រុមហ៊ុន RMAC បានរៀបចំបើកសម្ពោធរថយន្តថ្មី "The All-New Defender 2020" នៅសាខាតាំងបង្ហាញរថយន្ត Jaguar Land Rover របស់ក្រុមហ៊ុន។ ក្រុមហ៊ុន RMAC សម្រេចនាំចូលរថយន្តប្រណីតប្រភេទ Off-Road ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជនក្នុងស្រុក ក៏ដូចជាលើកទឹកចិត្តឱ្យប្រជាជនកម្ពុជាចាប់ផ្តើមប្រើប្រាស់រថយន្តម៉ាកថ្មីពីប្រភេទរថយន្ត Jaguar Land Rover.

**ការដាក់សម្ពោធជាផ្លូវការរបស់ The All-Fully Electric IPACE 2020 Jaguar**

នាថ្ងៃទី ៨ ខែតុលា ឆ្នាំ២០២០ ក្រុមហ៊ុន RMAC ដែលជាតំណាងចែកចាយផ្តាច់មុខនាំចូលរថយន្ត Jaguar Land Rover នៅកម្ពុជា បានរៀបចំបើកសម្ពោធរថយន្តថ្មី "The All-Fully Electric Jaguar IPACE 2020" នៅសាខាតាំងបង្ហាញរថយន្ត Jaguar Land Rover របស់ក្រុមហ៊ុន។ ក្រុមហ៊ុន **RMAC** សម្រេចនាំចូលរថយន្តប្រើអគ្គិសនីនេះ ព្រោះតែភាពល្អប្រើប្រាស់របស់វាអត្ថប្រយោជន៍ដែលរួមមាន ការចំនាយតិច ងាយស្រួលប្រើ មិនបញ្ចេញឧស្ម័នពុល និងភាពប្លែកពីគេរបស់រថយន្ត។

**ការដាក់សម្ពោធជាផ្លូវការរបស់ Ford Evrest 2,0L Bi-Turbo**

នាថ្ងៃទី ០២ ខែតុលា ឆ្នាំ២០២០ ក្រុមហ៊ុន RMAC បានរៀបចំបើកសម្ពោធ "Ford Everest 2.0L Bi-Turbo – VIP Dinner" នៅ The Premier Center សាខាសែន សុខ។ រថយន្ត Ford Everest គឺប្រភេទរថយន្តល្អជាងគេបំផុតក្នុងលំដាប់ SUV ដែលបានផ្តោតសំខាន់ទៅលើសុវត្ថិភាពរបស់អ្នកបើកបរ និងអ្នកដំណើរ ការសន្សំសំចៃប្រេងឥន្ធនៈរួមជាមួយនឹងបច្ចេកវិទ្យាទំនើបបំផុតរបស់ម៉ាស៊ីន Bi-Turbo។

**ត្រាក់ទ័រ John Deer ក្នុងទស្សនកិច្ចរបស់សម្តេចតេជោ នៅខេត្តតាកែវ**

នាថ្ងៃទី ២១ កក្កដា ឆ្នាំ២០២០ សម្តេចតេជោបានបើត្រាក់ទ័រ John Deer ក្នុងទស្សនកិច្ចរបស់សម្តេចក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ដើម្បីលើស្ទួយការអភិវឌ្ឍវិស័យកសិកម្ម និងលើកឡើងពីសមិទ្ធផលសម្រេចបានក្នុងវិស័យនេះ។ គោលបំណងរបស់សម្តេចតេជោគឺចង់បង្ហាញពីភាពរីកចម្រើនរបស់គ្រឿងចក្រកសិកម្ម និងបង្ហាញពីវឌ្ឍនភាពរបស់វិស័យកសិកម្មក្នុងប្រទេស។ នៅក្នុងទស្សនកិច្ចនោះ សម្តេចតេជោបានពិនិត្យ និងបានបើកត្រាក់ទ័រ John Deer ដែលមានរូបភាពផ្សព្វផ្សាយក្នុងសារពត៌មានក្នុងស្រុក។

ក្នុងខែធ្នូឆ្នាំ ២០២០ ក្រុមហ៊ុនបាននាំចូលនូវត្រាក់ទ័រ John Deere ម៉ូដែល ៦០៩៥ (៩៥ HP)ផងដែរ។

**ពានរង្វាន់រូបិយប័ណ្ណនាំមុខគេក្នុងស្រុក(Best Local Currency Bond Award)**

ក្រុមហ៊ុន RMAC មានមោទនភាពយ៉ាងខ្លាំងដែលបានក្លាយជាស្ថាប័នដំបូងគេមួយដែលមិនមែនជាស្ថាប័នហិរញ្ញវត្ថុ ដែលបានបង្កើនដើមទុននៅក្នុងទីផ្សារភាគហ៊ុនកម្ពុជា និងទទួលបានពានរង្វាន់ Best Local Currency Bond Award នៅក្នុងកម្មវិធី Asset Asian Awards ឆ្នាំ២០២០ ហើយនេះក៏ជាលើកទីមួយផងដែរ ដែលស្ថាប័នឥណទាន និងវិនិយោគនៃAsian Development Bank បានផ្តល់ការធានាដល់សាជីវកម្មនៅក្នុងប្រទេសកម្ពុជា។




### ក្រុមហ៊ុន RMAC បានផ្តល់ជំនួយដល់កាកបាទក្រហមកម្ពុជាក្នុងពេលគ្រោះទឹកជំនន់

នាថ្ងៃទី ២៧ ឆ្នាំ២០២០ នៅទីស្នាក់ការកណ្តាលរបស់កាកបាទក្រហមកម្ពុជា លោក ងន សាំង នាយកប្រតិបត្តិការក្រុមហ៊ុន RMAC រួមជាមួយគណៈគ្រប់គ្រងក្រុមហ៊ុនបានជួបសំណេះសំណាល និងប្រគល់ជូននូវអង្ករចំនួន ២០តោន ទឹកត្រីចំនួន ១០០០យួរ និងទឹកស៊ីអ៊ីវចំនួន ១០០០យួរ ដល់កាកបាទក្រហមកម្ពុជាដើម្បីគាំទ្រដល់សកម្មភាពមនុស្សធម៌ខណៈពេលដែលប្រទេសកម្ពុជាកំពុងរងគ្រោះទឹកជំនន់នៅតាមបណ្តាខេត្តជាច្រើន។ ពិធីនេះត្រូវបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅផងដែរ ពីសំណាក់លោកជំទាវ ពុំ ចាន់ធីនី ដែលជាអគ្គលេខាធិការកាកបាទក្រហមកម្ពុជា និងជាតំណាងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រានីហ៊ុនសែន រួមជាមួយនឹងមន្ត្រីកាកបាទក្រហមជាច្រើនរូបទៀតផង។

### ការទទួលពានរង្វាន់ Runner-up Award ក្នុងកម្មវិធី CSR Excellence

នាថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២០ សភាពាណិជ្ជកម្មអាមេរិចបានបើកកិច្ចប្រជុំប្រចាំឆ្នាំ នៅសណ្ឋាគារ Raffles Hotel Le Royal ដែលមានអ្នកចូលរួមដូចជា លោក W. Patrick Murphy ឯកអគ្គរដ្ឋទូតប្រចាំនៅសហរដ្ឋអាមេរិកលោក លោក Chea Serey អគ្គនាយកនៃធនាគារជាតិកម្ពុជា លោក Buon Sarakmony រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម គណៈអភិបាល AmCham ២០២០ និងសមាជិកទាំងអស់ផងដែរ។

សម្រាប់ការទទួលពានរង្វាន់ Runner-up Award ក្នុងកម្មវិធី CSR Excellenceរបស់ក្រុមហ៊ុន RMAC ក្នុងឆ្នាំ២០២០ ក្រុមហ៊ុនបានធ្វើការចាប់ដៃគូរជាមួយ Ford Motor Company បរិច្ចាគ Ford Wildtrakចំនួន ១០គ្រឿងដល់សកលវិទ្យាល័យផ្នែកបច្ចេកទេសចំនួនបួនផ្សេងគ្នាក្នុងប្រទេសកម្ពុជា ដែលក្នុងនោះរួមមានមជ្ឈមណ្ឌលបណ្តុះបណ្តាលការសាងសង់ និងការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់វិទ្យាស្ថានផ្សេងៗ។ គោលបំណងនៃការបរិច្ចាគនេះ គឺដើម្បីផ្តល់ឱកាសដល់សិស្សានុសិស្សទាំងអស់ដែលសិក្សាជំនាញបច្ចេកទេសនៅសាលាបច្ចេកទេសទាំងអស់ដែលនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរួមជាមួយនឹងសាលាបច្ចេកទេសផ្សេងទៀតនៅទូទាំងប្រទេស។

ជាសេចក្តីបន្ថែម សូមអបអរសាទរដល់លោក Michael Berg ប្រធានផ្នែកអភិវឌ្ឍអាជីវកម្មរបស់ក្រុមហ៊ុន RMAC ដែលបានជាប់ឆ្នោតជ្រើសរើស ក្រុមប្រឹក្សាភិបាលរបស់ AmCham នៅក្នុងឆ្នាំ២០២១ ក្នុងកិច្ចប្រជុំទូទៅ។

## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

សមិទ្ធិផលសំខាន់ៗក្នុងត្រីមាសទី៤ នៃឆ្នាំ២០២០ រួមមាន៖

**<u>ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖</u>**

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០ រថយន្តម៉ាក Ford នៅតែរក្សាភាពឈានមុខគេក្នុងទីផ្សារ ដែលកាន់កាប់ចំណែកទីផ្សារភាគហ៊ុនចំនួន ៣៣,៧% សម្រាប់យានយន្តថ្មីក្នុងអំឡុងពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ បើប្រៀបធៀបទៅនឹង ៣៣,១% ក្នុងឆ្នាំ២០១៩។ រថយន្តម៉ាក Ford Ranger នៅតែបន្តជារថយន្តដែលលក់ដាច់ជាងគេក្នុងចំណោមទីផ្សាររថយន្តក្នុងប្រទេសកម្ពុជា។

**<u>គ្រឿងចក្រម៉ាក John Deere៖</u>** នៅជាអ្នកនាំមុខទី២នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា។

**<u>លទ្ធផលហិរញ្ញវត្ថុ៖</u>**

ក្រុមហ៊ុន RMAC ទទួលបានចំណូលចំនួន ២៦៥,៣ ប៊ីលានរៀល ក្នុងដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២០ ដែលមានការកើនឡើងចំនួន +២០,៧% ធៀបនឹងដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០១៩។ សម្រាប់ដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២០ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ១៤,៤ ប៊ីលានរៀល ដែលកើនឡើងចំនួន +១៥៤,០% ធៀបនឹងដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០១៩ ដោយសារតែ៖

- ប្រាក់ចំណេញដុលចំនួន ៧,៩ ប៊ីលានរៀល ក្នុងដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២០ បានមកពីកំណើនលក់នៅចុងឆ្នាំ២០២០ (ការលក់កើនឡើងចំនួន +៤៥,៥ ប៊ីលានរៀលបើប្រៀបធៀបទៅនឹងឆ្នាំមុន)។
- ប្រាក់ចំណាយបានធ្លាក់ចុះចំនួន ៤.៤ ប៊ីលានរៀល ជាពិសេសលើសំវិធានធនលើពន្ធក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ដែលមិនបានយកមកអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០២០ និងរួមផ្សំទាំងប្រាក់សន្សំផ្សេងទៀតក្នុងត្រីមាសទី៤ ឆ្នាំ២០២០។
- ទឹកប្រាក់ចំនួន ៤ ប៊ីលានរៀល ដែលបានមកពីផលប៉ះពាល់នៃនិយ័តកម្មលើពន្ធពន្យារក្នុងត្រីមាសទី៤ ឆ្នាំ២០២០ និងត្រីមាសទី៤ ឆ្នាំ២០១៩។

ហើយពត៌មានហិរញ្ញវត្ថុ (មិនទាន់ធ្វើសវនកម្ម) សំខាន់ៗសម្រាប់ដំណាច់ឆ្នាំនោះគឺ៖

- ទ្រព្យសកម្មសរុបរក្សានៅចំនួន ៥១៩ ប៊ីលានរៀល ដែលបានធ្លាក់ចុះចំនួន ៧៧ ប៊ីលានរៀល តាមរយៈការកាត់បន្ថយសារពើភណ្ឌ (ពីចំនួន ៣០៧ ប៊ីលានរៀលបើធៀបនឹងចុងឆ្នាំ២០១៩ ទៅ ១៥៣ ប៊ីលានរៀលនៅចុងឆ្នាំ២០២០) និងចំនួនទឹកប្រាក់ ៥១ ប៊ីលានរៀលនៃការធ្លាក់ចុះនៃបំណុលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ។
- ចំនួនទឹកប្រាក់ ១១៥ ប៊ីលានរៀលនៃទំហំសាច់ប្រាក់ (cash position) របស់ក្រុមហ៊ុន ត្រូវបានពង្រឹងដោយបានបង្កើនឡើងដល់ចំនួន ១៥៩ ប៊ីលានរៀល។

- មូលធនរបស់ម្ចាស់ភាគហ៊ុនមានត្រឹមចំនួន ១៨២ ប៊ីលានរៀល ដែលបានកើនឡើងចំនួន ៦២ ប៊ីលានរៀលធៀបនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។
- លទ្ធផលនៃលំហូរសាច់ប្រាក់សុទ្ធពីប្រតិបត្តិការក្នុងកំឡុងពេលពេញមួយឆ្នាំនៃឆ្នាំ២០២០ មានភាពរឹងមាំដែលមានចំនួន ២៥៤ ប៊ីលានរៀល ដែលបានកើនឡើងចំនួន ២៦១ ប៊ីលានរៀល ធៀបនឹង ឆ្នាំ ២០១៩ ហើយភាពកើនឡើងទាំងនេះគឺសុទ្ធតែជាផលដែលបានមកពីការកាត់បន្ថយសារពើភ័ណ្ឌផងដែរ។

ក្រុមហ៊ុន RMAC នៅតែបន្តធ្វើការវិនិយោគនូវសាច់ប្រាក់សុទ្ធចំនួន +១០,៦ ប៊ីលានរៀល ក្នុង ឆ្នាំ២០២០ ដោយរាប់បញ្ចូលទាំងការវិនិយោគប្រមាណជាង ៥ ប៊ីលានរៀលទៅលើការបង្កើតមជ្ឈមណ្ឌលផ្តល់សេវាកម្មរថយន្តម៉ាក Ford ថ្មី ដោយមានបំពាក់ជាមួយនូវគ្រឿងបរិក្ខារចុងក្រោយបំផុតដើម្បីអនុញ្ញាតឲ្យក្រុមការងាររបស់យើងខ្ញុំអាចផ្តល់សេវាកម្មលំដាប់ពិភពលោកជូនដល់អតិថិជនរបស់យើងខ្ញុំដែលកំពុងកើនឡើង។

## ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Jaguar Land Rover, Fuso, John Deere និង JCB។ ក្នុងអំឡុងពេលដែលវិស័យអាជីវកម្មផ្សេងៗកំពុងតែអភិវឌ្ឍខ្លួន អាជីវកម្ម Ford ក៏បានដើរតួរជាវិស័យចម្បងមួយនៃរចនាសម្ព័ន្ធប្រាក់ចំណូលរបស់ក្រុមហ៊ុននាពេលបច្ចុប្បន្ននេះផងដែរ។ អាជីវកម្ម Ford ដែលរួមមានការលក់យានយន្ត សេវាកម្មក្រោយការលក់ និងការលក់គ្រឿងបន្លាស់ដែលបានផ្តល់ចំណូលជាង ៨២,៥% នៃប្រាក់ចំណូលសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០ (បើធៀបនឹង ៨៣,៤% នៃប្រាក់ចំណូលសម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៩) និងប្រាក់ចំណូលដំណាច់ឆ្នាំ២០២០ មានចំនួន ៨៧,២% (បើធៀបនឹង ៨៦,១% នៃប្រាក់ចំណូលដំណាច់ឆ្នាំ២០១៩)។

ចំណូលទទួលបានតាមផ្នែក ត្រូវបានបង្ហាញក្នុងផ្នែកទី៤ នៃរបាយការណ៍នេះ។

## ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមយោងទៅកាន់ឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នប្រចាំត្រីមាស និងរយៈពេល ១២ ខែគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

**<u>ត្រីមាសទី ឆ្នាំ២០២០ ធៀបនឹងត្រីមាសទី ឆ្នាំ២០១៩</u>**៖ ចំណូលសរុប មានចំនួន ២៦៥,៣ប៊ីលានរៀល ត្រូវបានកើនឡើងចំនួន +៤៥,៥ ប៊ីលានរៀល ឬ +២០,៧ ភាគរយ នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០ បើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩។

**<u>ឆ្នាំ២០២០ ធៀបនឹងឆ្នាំ២០១៩</u>**៖ ចំណូលសរុប មានចំនួន ១,១៩៦ ប៊ីលានរៀល សម្រាប់ ឆ្នាំ២០២០ ដែលបានកើនឡើងចំនួន +៤,១% បើធៀប ឆ្នាំ២០១៩ មានប្រាក់ចំណូលចំនួន ១.១៤៨,៦ ប៊ីលានរៀល ដែលសបញ្ជាក់អោយឃើញពីភាពរឹងមាំនៃត្រីមាសទី ១ ឆ្នាំ ២០២០ ស្របជាមួយនឹងការធ្លាក់ចុះក្នុងត្រីមាសទី២ ឆ្នាំ២០២០ (ចំនួន ៨០,៩% ទាបជាងការលក់ក្នុងត្រីមាសទី២ នៃឆ្នាំ២០១៩) ដោយសារការរាតត្បាតនៃវីរុសកូវីដ-១៩។ ប្រាក់ចំណូលក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ដែលមានការកើនឡើងជាបន្តបន្ទាប់ ថ្វីបើតួលេខសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២០ មានភាពទាបជាងត្រីមាសទី៣ ឆ្នាំ ២០១៩ (ចំនួន -០.៤%) ហើយចំពោះប្រាក់ចំណូលត្រីមាសទី៤ ឆ្នាំ២០២០ មានចំនួន ២០,៧% ខ្ពស់ជាងត្រីមាសទី៤ ឆ្នាំ ២០២០ ។

### ២. ផ្នែកនៃចំណូល

| គិតពាន់រៀល | ត្រីមាសទី៤ ឆ្នាំ ២០២០ | ភាគរយនៃភាគហ៊ុន | ត្រីមាសទី៤ ឆ្នាំ ២០១៩ | ភាគរយនៃភាគហ៊ុន |
|---|---|---|---|---|
| Ford | ២១៨.៩១៩.៣៩៩ | ៨២,៥% | ១៨៣.៣៧៩.៨៨៦ | ៨៣,៤% |
| ប្រតិបត្តិការផ្សេងទៀត | ៥១.០៩៧.៨៤៦ | ១៩,៣% | ៤១.៦៩៤.៦៧០ | ១៩,០% |
| ការលុបបំបាត់សាជីវកម្ម (Corporate Elimination) | (៤.៧២២.៣១១) | -១,៨% | (៥.២៧២.៧៥៥) | -២,៤% |
| សរុប | ២៦៥.២៩៤.៩៣៤ | ១០០,០% | ២១៩.៨០១.៨០១ | ១០០,០% |

| គិតជាពាន់រៀល | ក្នុងឆ្នាំ ២០២០ | ភាគរយនៃភាគហ៊ុន | ក្នុងឆ្នាំ ២០១៩ | ភាគរយនៃភាគហ៊ុន |
|---|---|---|---|---|
| Ford | ១.០៤៣.៤៧២.៦០៤ | ៨៧,២% | ៩៨៨.៥៩៤.៨៩១ | ៨៦,១% |
| ប្រតិបត្តិការផ្សេងទៀត | ១៧២.១៨២.០៤៧ | ១៤,៤% | ១៧៨.៦០០.៨៥២ | ១៥,៦% |
| ការលុបបំបាត់សាជីវកម្ម | (១៩.៦០៤.៨៧៤) | -១,៦% | (១៨.៦១០.៣៨៩) | -១,៦% |

| | | | | |
|---|---|---|---|---|
| (Corporate Elimination) | | | | |
| សរុប | ១.១៩៦.០៥០.១៧៧ | ១០០,០% | ១.១៩៨.៥៨៥.៣៥៥ | ១០០,% |

**<u>ត្រីមាសទី៤ ឆ្នាំ២០២០ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩៖</u>**

បានកើនឡើងចំនួន ៣៥,៥ ប៊ីលានរៀន (+១៩,៥%ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩) ដោយឆ្លុះបញ្ចាំងឲ្យឃើញពីការលក់របស់ក្រុមហ៊ុនកាន់តែខ្ពស់ ។ ចំណូលដែលបានមកពីប្រតិបត្តិការផ្សេងទៀត ត្រូវបានធ្លាក់ចុះចំនួន -៥១,១ ប៊ីលានរៀល (កើនឡើងចំនួន +២២,៦% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩) ជាមួយនឹងបរិមាណកើនឡើងសម្រាប់ម៉ាក JLR JOHN DEERE JCB និងFUSO។

**<u>ឆ្នាំ២០២០ ធៀបនឹងឆ្នាំ២០១៩</u>៖** ចំណូលរបស់ Ford សម្រាប់ឆ្នាំ២០២០ បានកើនឡើងចំនួន ៥៥,៩ ប៊ីលានរៀល ធៀបនឹងឆ្នាំ២០១៩ (កើនឡើងចំនួន +៥,៦%) ដែលបានសបញ្ជាក់អោយឃើញពីភាពរឹងមាំនៃត្រីមាសទី១ និងត្រីមាសទី៤ ឆ្នាំ២០២០ ប៉ុន្តែចំណូលនេះ ត្រូវបានកាត់កងដោយការធ្លាក់ចុះនូវបរិមាណលក់ដែលមានចំនួនទាបនៅក្នុងត្រីមាសទី២ និង ត្រីមាសទី៣ នៃឆ្នាំ២០២០ ដែលបណ្តាលមកពីផលប៉ះពាល់នៃវីរុសកូវីដ-១៩។ ចំណូលនៃប្រតិបត្តិការផ្សេងទៀតត្រូវបានថយចុះចំនួន ៦,៤ ប៊ីលានរៀល (ថយចុះ -៣,៦% ធៀបនឹងឆ្នាំ២០១៩) ដែលបណ្តាលមកពីផលប៉ះពាល់នៃវីរុសកូវីដ-១៩ ជាពិសេសក្នុងត្រីមាសទី២ ឆ្នាំ២០២០។

## ៣. គម្លាតចំណេញដុល

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ ២០២០ | ត្រីមាសទី៤ ឆ្នាំ ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ២៦៥.២៩៤.៩៣៤ | ២១៩.៨០១.៨០១ | ៤៥.៤៩៣.១៣៣ | ២០,៧% |
| ចំណេញដុល | ៤០.៧១៨.៦០២ | ៣២.៨៤៣.៦៧៨ | ៧.៨៧៤.៩២៤ | ២៤,០% |
| គម្លាតចំណេញដុល | ១៥,៣% | ១៤,៩% | មិនមាន | មិនមាន |

| គិតជាពាន់រៀល | ក្នុងឆ្នាំ ២០២០ | ក្នុងឆ្នាំ ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ១.១៩៦.០៥០.១៧៧ | ១.១៩៨.៥៨៥.៣៥៥ | ៤៧.៤៦៤.៨២៣ | ៤,១% |
| ចំណេញដុល | ១៨៨.៨៩៤.៨៥៤ | ១៨៧.៩៥៣.៨៣៦ | ៩៤១.០១៨ | ០,៥% |
| គម្លាតចំណេញដុល | ១៥,៨% | ១៦,៤% | មិនមាន | មិនមាន |

**ត្រីមាសទី៤ ឆ្នាំ២០២០ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩៖** គម្លាតចំណេញដុលនៃត្រីមាសទី៤ ឆ្នាំ២០២០ បានកើនឡើងចំនួន ១៥,៣% (ធៀបនឹង ១៤,៩% នៃត្រីមាសទី៤ ឆ្នាំ២០១៩) ដោយសារការលក់នូវផលិតផលចម្រុះ និងម៉ាកថ្មីៗដែលឆ្លើយតបទៅនឹងការប្រកួតប្រជែងក្នុងទីផ្សារ។

**ឆ្នាំ២០២០ ធៀបនឹង ឆ្នាំ២០១៩៖** គម្លាតចំណេញដុលសម្រាប់ឆ្នាំ២០២០មានចំនួន ១៥,៨% ដែលទាបជាងគម្លាតចំណេញដុល ក្នុងឆ្នាំ២០១៩ ចំនួន ១៦,៤% ដែលបណ្តាលមកពី ការប្រកួតប្រជែងក្នុងទីផ្សារនៅអំឡុងពេលកូវីត-១៩។

## ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ ២០២០ | ត្រីមាសទី៤ ឆ្នាំ ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ២៦៥.២៩៤.៩៣៤ | ២១៩.៨០១.៨០១ | ៤៥.៤៩៣.១៣៣ | ២០,៧% |
| ចំណេញដុល | ៤០.៧១៨.៦០២ | ៣២.៨៤៣.៦៧៨ | ៧.៨៧៤.៩២៤ | ២៤,០% |
| គម្លាតចំណេញដុល | ១៥,៣% | ១៤,៩% | មិនមាន | មិនមាន |
| ចំណាយ | ២១.៩៦១.៩០៩ | ២៦.៣៧១.៦២៧ | (៤០៩.៧១៨) | -១៦.៧% |
| ចំណាយហិរញ្ញវត្ថុ | ២.២០៥.៦៧៦ | ២.៧៦១.១៥៩ | (៥៥៥.៤៨៣) | -២០,១% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៦.៥៥១.០១៧ | ៣.៧១០.៨៩២ | ១២.៨៤០.១២៥ | ៣៤៦,០% |
| គម្លាត | ៦,២% | ១,៧% | | |

| គិតជាពាន់រៀល | ក្នុងឆ្នាំ ២០២០ | ក្នុងឆ្នាំ ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ១.១៩៦.០៥០.១៧៧ | ១.១៤៨.៥៨៥.៣៥៤ | ៤៧.៤៦៤.៨២៣ | ៤,១% |
| ចំណេញដុល | ១៨៨.៨៩៤.៨៥៤ | ១៨៧.៩៥៣.៨៣៦ | ៩៤១.០១៨ | ០,៥% |
| គម្លាតចំណេញដុល | ១៥,៨% | ១៦,៤% | មិនមាន | មិនមាន |
| ចំណាយ | ៦៣.៤៣៦.០៤៩ | ៦៤.៩៦១.៥២៨ | ១.៥២៥.៤៧៩ | -២,៣% |
| ចំណាយហិរញ្ញវត្ថុ | ១៤.៧៨៦.៩៨៨ | ៩.៥៩៤.៦៩០ | ៥.១៩២.២៩៨ | ៥៤,១% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ១១០.៦៧១.៨១៧ | ១១៣.៣៩៧.៦១៨ | ២.៧២៥.៨០១ | -២,៤% |
| គម្លាត | ៩,៣% | ៩,៩% | | |

**ត្រីមាសទី៤ ឆ្នាំ២០២០ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩៖** គម្លាតប្រាក់ចំណេញមុនបង់ពន្ធ សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០ មានចំនួន ៦,២% កើនឡើងពីចំនួន ១,៧% ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ដោយសារហេតុផលបីយ៉ាងគឺ កំណើននៃ

ការលក់ ការកាត់បន្ថយលើចំណាយប្រតិបត្តិការ ជាពិសេសលើការបង់ពន្ធក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ និង តម្លៃហិរញ្ញវត្ថុទាបដោយសារទំហំសាច់ប្រាក់ខ្ពស់ ហើយនិងការសងប្រាក់កម្ចីក្នុងរយៈពេលខ្លី និងឆាប់រហ័ស។

**ឆ្នាំ២០២០ ធៀបនឹង ឆ្នាំ២០១៩៖** គម្លាតប្រាក់ចំណេញសរុបមុនបង់ពន្ធ ត្រូវបានថយចុះពី ៩,៩% ក្នុងឆ្នាំ២០១៩ មកនៅត្រឹម ៩% ក្នុងឆ្នាំ២០២០ ដែលសបញ្ជាក់ឲ្យឃើញពីធ្លាក់ចុះ (១៥,៨% ធៀបនឹង ១៦,៤% ឆ្នាំ២០១៩) ការធ្លាក់ចុះនៃការចំណាយចំនួន ១,៥ ប៊ីលានរៀលគឺដោយសារវិធានការបង់ពន្ធក្នុងឆ្នាំ២០១៩ ចំណែកឯហិរញ្ញវត្ថុដែលកើនឡើងចំនួន ៥,២ ប៊ីលានរៀលគឺដោយសារយុទ្ធសាស្ត្រកាត់បន្ថយចំណាយក្នុងអំឡុងពេលជម្ងឺរាតត្បាតកូវីដ-១៩។

## ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ ២០២០ | ត្រីមាសទី៤ ឆ្នាំ ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៦.៥៥១.០១៧ | ៣.៧១០.៨៩២ | ១២.៨៤០.១២៥ | ៣៤៦,០% |
| ចំណាយពន្ធ | ២.១៣២.៧៧៥ | ១.៩៦៥.០៣១ | ៤.០៩៧.៨០៦ | ២០៨,៥% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ១៤.៤១៨.២៤២ | ៥.៦៧៥.៩២៣ | ៨.៧៤២.៣១៩ | ១៥៤,០% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ៥,៤% | ២.៦% | មិនមាន | មិនមាន |

| គិតជាពាន់រៀល | ឆ្នាំ ២០២០ | ឆ្នាំ ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ១១០.៦៧១.៨១៧ | ១១៣.៣៩៧.៦១៨ | ២.៧២៥.៨០១ | -២,៤% |
| ចំណាយពន្ធ | ២១.៦២០.៥៥១ | ២២.៧៦៨.៧៣៥ | ១.១៤៨.១៨៤ | -៥,០% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ៨៩.០៥១.២៦៦ | ៩០.៦២៨.៨៨៣ | ៥៧៧.៦១៧ | -១,៧% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ៧,៤% | ៧,៩% | មិនមាន | មិនមាន |

**ត្រីមាសទី៤ ឆ្នាំ២០២០ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩៖** គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ សម្រាប់ត្រីមាសទី ៤ ឆ្នាំ ២០២០ មានចំនួន ៥,៤% កើនឡើងពីចំនួន ២,៦% ក្នុងត្រីមាសទី៤ ឆ្នាំ ២០១៩ ដែលបណ្តាលមកពីគម្លាតប្រាក់ចំណេញមុនបង់ពន្ធក្នុងត្រីមាសទី៤ ឆ្នាំ ២០២០ និងការពន្យាពេលបង់ពន្ធ។

**ឆ្នាំ២០២០ ធៀបនឹង ឆ្នាំ២០១៩៖** គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធក្នុងឆ្នាំ២០២០ មានចំនួន ៧,៤% ដែលបានថយចុះពីចំនួន ៧,៩% ក្នុងឆ្នាំ២០១៩ ដែលបណ្តាលមកពីការធ្លាក់ចុះនៃគម្លាតចំនេញ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ការរាតត្បាតនូវវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាបានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងទាំងតម្រូវការ និងការផ្គត់ផ្គង់ ជាពិសេសនៅក្នុងដំណាច់ត្រីមាសទី២ ឆ្នាំ២០២០។ តម្រូវការ ត្រូវបានប៉ះពាល់តាមរយៈការពន្យារពេល និងការលុបចោលនូវគម្រោងឯកជន និងគម្រោងសាធារណៈធំៗ ការធ្លាក់ចុះនូវជំនឿទុកចិត្តរបស់អតិថិជន ការខាតបង់របស់អាជីវកម្មទេសចរណ៍ បដិសណ្ឋាកិច្ច និង ភាពតឹងរឹងជាងមុនចំពោះកម្ចីធនាគារ។ ដោយនៅដំណាច់ត្រីមាសទី៤ ការផ្គត់ផ្គង់ ត្រូវបានប៉ះពាល់ដោយការបិទទីក្រុង ជាពិសេស រោងចក្រ Ford នៅប្រទេសថៃ ប៉ុន្តែបន្ទាប់មកទៀតក៏បានត្រលប់មករកភាពធម្មតាវិញ។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។ ប៉ុន្តែតម្លៃដឹកជញ្ជូនបានកើនឡើង ក្នុងកំឡុងការរាតត្បាតនៃមេរោគ កូវិត ១៩។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

គួរបញ្ជាក់ផងដែរថា របាយការណ៍ហិរញ្ញវត្ថុក្នុងរបាយការណ៍នេះ ត្រូវបានធ្វើឡើងដោយពិចារណាដល់ការអនុគ្រោះលើការកំណត់ពន្ធឡើងវិញដល់បុគ្គលបោះផ្សាយមូលបត្រ យោងតាមអនុក្រឹត្យលេខ ០១អនក្រ.បក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ("អនុក្រឹត្យ")។ ដូចមានបញ្ជាក់ក្នុងឯកសារផ្តល់ពត៌មានរបស់ក្រុមហ៊ុន RMAC ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ភាពមិនច្បាស់លាស់នៅតែមានទាក់ទងនឹងការស្នើសុំការអនុគ្រោះពន្ធ (តាមអនុក្រឹត្យខាងលើ) សម្រាប់ឆ្នាំបង់ពន្ធមួយចំនួន ។ បច្ចុប្បន្នក្រុមហ៊ុនយើងខ្ញុំកំពុងធ្វើការជាមួយគ.ម.កលើការអនុវត្តអនុក្រឹត្យលេខ ០១ អនក្រ.បក ស្តីពីការលើកទឹកចិត្តពន្ធដារលើវិស័យមូលបត្រ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ.	ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០ និងក្នុងរយៈពេលពេញមួយឆ្នាំ ២០២០ និង ប្រៀបធៀបរយៈពេលនេះជាមួយនឹងឆ្នាំ ២០១៩ ត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ.	ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង.	ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច.	គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

មិនមានផលប៉ះពាល់ចំបងណាមួយដែលបណ្តាលមកពីការប្រែប្រួលនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលឡើយ ក្រៅពីគោលនយោបាយដែលពាក់ព័ន្ធនឹងវីរុសកូវីដ-១៩ ដែលរួមមានការកាត់បន្ថយចំណាយរដ្ឋ និងការរឹតត្បឹតលើវិស័យមួយចំនួនដល់សេដ្ឋកិច្ចជាតិ ដូចជាវិស័យទេសចរណ៍។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១

| | |
|---|---|
| បានអាន និង អនុម័ត | បានអាន និង អនុម័ត |
| ឈ្មោះ Kevin Whitcraft | ឈ្មោះ ងន សាំង |
| តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល | តួនាទី៖ នាយកប្រតិបត្តិ |